៧- សមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជាគ្រប់ថ្នាក់ ត្រូវបន្តពង្រឹងពង្រីកសកម្មភាពរបស់សមាគមតាមស្មារតីនៃសេចក្តីសម្រេចចិត្តមហាសន្និបាតវិសាមញ្ញតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស។ សមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា ត្រូវបន្តធ្វើជាស្នូលក្នុងការលើកកម្ពស់តួនាទីអតីតយុទ្ធជន និងនិវត្តជននៅក្នុងសង្គមជាតិ និងលើកទឹកចិត្តឱ្យបងប្អូនអតីតយុទ្ធជន និងនិវត្តជនប្រកាន់ខ្ជាប់នូវស្មារតីសាមគ្គីភាព និងការជួយជ្រោមជ្រែងគ្នាទៅវិញទៅមក ព្រមទាំងចូលរួមឱ្យបានសកម្មក្នុងចលនាប្រឡងប្រណាំងពពូកែ (ការធ្វើសេដ្ឋកិច្ចគ្រួសារពូកែ ការជួយគ្នាដើម្បីកាត់បន្ថយភាពក្រីក្រពូកែ ការអភិវឌ្ឍសហគមន៍និងសង្គមជាតិពូកែ) ដើម្បីជាប្រយោជន៍ដល់បងប្អូននិងប្រទេសជាតិ។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយនិងប្រគេនពរសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចសង្ឃនាយក ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សូមថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** និងសូមថ្វាយព្រះពរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមព្រះអង្គមានព្រះរាជសុខភាពមាំមួន ព្រះជន្មាយុយឺនយូរ ដើម្បីគង់ជាម្លប់ដ៏ត្រជាក់សម្រាប់កូនចៅ ចៅទួតរបស់ព្រះអង្គយូរអង្វែងតរៀងទៅ និងសូមប្រសិទ្ធពរជ័យជូនសម្តេច ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី បងប្អូនអតីតយុទ្ធជន អតីតមន្ត្រីរាជការស៊ីវិល និងជនរួមជាតិទាំងអស់ សូមសមប្រកបដោយពុទ្ធពរបួនប្រការ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃសុក្រ ៨រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមសម្តែងនូវកតញ្ញូកតវេទិតាធម៌ថ្វាយចំពោះ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ដែលព្រះអង្គតែងតែយកព្រះទ័យទុកដាក់ចំពោះប្រជារាស្ត្ររបស់ព្រះអង្គ ជាពិសេសតែងតែផ្តល់ការគាំទ្រដល់អតីតយុទ្ធជន អតីតមន្ត្រីរាជការស៊ីវិល និងគ្រួសារជនពលីមរណៈ ប្រកបដោយព្រះទ័យព្រហ្មវិហារធម៌ដ៏ជ្រាលជ្រៅបំផុត។

ខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះកាកបាទក្រហមកម្ពុជា ដៃគូអភិវឌ្ឍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ព្រមទាំងសប្បុរសជនទាំងអស់ ដែលបានយកចិត្តទុកដាក់ផ្តល់ជំនួយឧបត្ថម្ភគាំទ្រដល់បងប្អូនអតីតយុទ្ធជន និវត្តជន និងក្រុមគ្រួសារ ក៏ដូចជាជនចាស់ជរា ជនពិការ ស្ត្រីមេម៉ាយ និងគ្រួសារយុទ្ធជនពលីមរណៈ ដែលមានជីវភាពលំបាក សំដៅចូលរួមចំណែកលើកកម្ពស់កម្រិតជីវភាពនិងសុខុមាលភាពរបស់បងប្អូន។ ទឹកចិត្តនិងកាយវិការដ៏សប្បុរសនេះបានឆ្លុះបញ្ចាំងឱ្យឃើញអំពីស្មារតីនៃការជួយគ្នាទៅវិញទៅមកនៅគ្រប់កាលៈទេសៈ គ្រប់ទីកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសខួបលើកទី១៩ ទិវាអតីតយុទ្ធជន និងនិវត្តជនកម្ពុជានេះ ខ្ញុំសូមអំពាវនាវដូចតទៅ៖

១- បងប្អូនអតីតយុទ្ធជន និងនិវត្តជន សូមបន្តរក្សាស្មារតីវីរភាពដ៏ឧត្តុង្គឧត្តមនិងសេចក្តីថ្លៃថ្នូរ ជាពលរដ្ឋឆ្នើមរបស់ជាតិមាតុភូមិ ដើម្បីបន្តធ្វើជាគំរូល្អក្នុងសង្គមជាតិ។ រាជរដ្ឋាភិបាលនិងប្រជាជនទូទាំងប្រទេសពិតជាចងចាំជានិច្ចនូវការលះបង់និងគុណបំណាច់ដ៏ធំធេងរបស់បងប្អូនអតីតយុទ្ធជន និងនិវត្តជនគ្រប់រូប ចំពោះជាតិមាតុភូមិជាទីស្នេហានៃយើង។

២- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគណៈប្រតិភូចុះសួរសុខទុក្ខអតីតយុទ្ធជន និវត្តជននៅតាមមូលដ្ឋាន និងយុទ្ធជន យុទ្ធនារី ដែលកំពុងបំពេញបេសកកម្មនៅតំបន់ព្រំដែន ដែនកោះ និងកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ និងជនពិការនៅតាមមណ្ឌលអភិវឌ្ឍន៍យោធិនពិការ ដើម្បីផ្សារភ្ជាប់មនោសញ្ចេតនា និងលើកទឹកចិត្តដល់អតីតយុទ្ធជន យុទ្ធជន និងយុទ្ធនារីទាំងអស់។

៣- ក្រសួងព័ត៌មានត្រូវណែនាំឱ្យប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋនិងឯកជនផ្សព្វផ្សាយសារាចររបស់រាជរដ្ឋាភិបាល ក្នុងឱកាសខួបលើកទី១៩ ទិវាអតីតយុទ្ធជន និងនិវត្តជនកម្ពុជា ១២ ឧសភា ក៏ដូចជាសមិទ្ធផលនានាពាក់ព័ន្ធនឹងវិស័យអតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិលឱ្យសាធារណជនជាតិនិងអន្តរជាតិបានយល់ដឹងជ្រួតជ្រាបកាន់តែទូលំទូលាយបន្ថែមទៀត។

៤- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបន្តអនុវត្តឱ្យបានល្អនិងមានប្រសិទ្ធភាពនូវការផ្តល់សេវាគាំពារសុខុមាលភាពអតីតយុទ្ធជន និវត្តជន និងការផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន អតីតមន្ត្រីរាជការស៊ីវិល និងគ្រួសារ តាមរយៈមូលនិធិជាតិជំនួយសង្គមនៅទូទាំងប្រទេស។ ម្យ៉ាងវិញទៀត ក្រសួងត្រូវខិតខំជំរុញការអនុវត្តគម្រោងសាងសង់ផ្ទះជូនអតីតយុទ្ធជន អតីតមន្ត្រីរាជការស៊ីវិល និងគ្រួសារដែលក្រីក្រ ដូចដែលបានបញ្ចូលក្នុងផែនការវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល។

៥- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ បន្តជំរុញការអនុវត្តគោលនយោបាយស្តីពីការផ្តល់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

៦- ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវចូលរួមក្នុងការជួយឧបត្ថម្ភគាំទ្រដល់អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល ជាពិសេសត្រូវយកចិត្តទុកដាក់ជួយឧបត្ថម្ភគាំទ្រដល់គ្រួសារអតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល ដែលកំពុងជួបប្រទះការលំបាក។

បច្ចុប្បន្ន ចំនួនអតីតយុទ្ធជន និងនិវត្តជន មានចំនួនសរុប ១៧៧ ២៨១នាក់ ដែលកំពុងទទួលប្រាក់របបសន្តិសុខសង្គមប្រចាំខែពីរដ្ឋក្នុងនោះ អតីតយុទ្ធជនចំនួន ១១៩ ៣២៦នាក់ ព្រមទាំងអ្នកនៅក្នុងបន្ទុកចំនួន ១៦២ ៣៩៨នាក់ ចំណាយថវិកាចំនួន ៨៨ ៧៦២ ០៦០ ៩១៤រៀល ស្មើនឹង ២២ ១៩០ ៥១៦ដុល្លារអាម៉េរិក (គិតត្រឹមខែធ្នូ ឆ្នាំ២០២៥)។ ចាប់ពីខែមករា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនគ្រួសាររបស់អតីតយុទ្ធជនពលីនិងមរណៈ និងប្រាក់ឧបត្ថម្ភប្ដីឬប្រពន្ធ ពី១៥ ០០០រៀល ទៅ៣០ ០០០រៀល កូនពី១០ ០០០រៀល ទៅ៣០ ០០០រៀល និងឪពុក ម្ដាយ ឬអាណាព្យាបាល ពី៨ ០០០រៀល ទៅ៣០ ០០០រៀល ក្នុងម្នាក់។ អតីតមន្ត្រីរាជការស៊ីវិល មានចំនួន ៥៧ ៩៥៥នាក់ និងអ្នកក្នុងបន្ទុកចំនួន ១៥ ៤៧៩នាក់ កំពុងទទួលប្រាក់របបសន្តិសុខសង្គមពីរដ្ឋ ដោយថវិកាចំណាយសរុបចំនួន ៥៣ ១៧៨ ៥០០ ៧៨៦រៀល ស្មើនឹង ១៣ ២៩៤ ១២៥ដុល្លារអាម៉េរិក (គិតត្រឹមខែធ្នូ ឆ្នាំ២០២៥)។ គិតចាប់ពីខែមេសា ឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានដំឡើងប្រាក់របបសន្តិសុខសង្គមប្រចាំខែអប្បបរមាជូននិវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលជាអតីតយុទ្ធជននិងនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈជាអតីតមន្ត្រីរាជការស៊ីវិល ឱ្យដល់៨៤៥ ០០០រៀលក្នុងមួយខែ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានផ្ដល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរចំនួន ៥០ ០០០រៀល និងពិធីបុណ្យភ្ជុំបិណ្ឌចំនួន ៥០ ០០០រៀល ជូនដល់អតីតមន្ត្រីរាជការស៊ីវិល និងនិវត្តជន ជនបាត់បង់សមត្ថភាពការងារ ជនពិការ គ្រួសារជនពលី និងគ្រួសារជនមរណៈជាអតីតយុទ្ធជន។

ទិន្នន័យអតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល ព្រមទាំងអ្នកនៅក្នុងបន្ទុក ត្រូវបានធ្វើបច្ចុប្បន្នកម្មនិងគ្រប់គ្រងតាមប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យា ដើម្បីធានាបាននូវប្រសិទ្ធភាពនិងសុវត្ថិភាពក្នុងការបើករបបសន្តិសុខសង្គមប្រចាំខែ ដែលកំពុងអនុវត្តជាមួយធនាគារដៃគូនៅទូទាំង២៥ រាជធានី ខេត្ត និងបើកប្រាក់របបសន្តិសុខសង្គមរៀងរាល់ពីរសប្ដាហ៍ម្ដងក្នុងខែនីមួយៗ ដែលត្រូវបានដាក់ឱ្យអនុវត្តចាប់ពីខែមករា ឆ្នាំ២០១៩។ រាជរដ្ឋាភិបាលបានផ្ដល់បណ្ណថែទាំសុខភាព ប.ស.ស. ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារជាអតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល និងបណ្ណមូលនិធិសមធម៌សុខាភិបាលជូនអ្នកកាន់សៀវភៅរបស់គ្រួសារជនពលី និងគ្រួសារជនមរណៈជាអតីតយុទ្ធជន ដើម្បីទៅព្យាបាលជំងឺនៅតាមមន្ទីរពេទ្យដែលបានចុះកិច្ចសន្យាជាមួយ ប.ស.ស. ដោយមិនបង់ប្រាក់។

គិតចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០២៥ តាមរយៈព្រះរាជអំណោយដ៏ថ្លៃថ្លារបស់ **សម្ដេចព្រះមហាក្សត្រី នរោត្ដម មុនិនាថ សីហនុ** និងអំណោយដ៏ថ្លៃថ្លារបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និងសម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ព្រមទាំងសប្បុរសជននានា បានសាងសង់ (១)- ផ្ទះសរុបបានចំនួនប្រមាណ ៧ ៥០០ខ្នងផ្ទះ ដែលក្នុងនោះមានការសាងសង់នៅលើទីតាំងដីលំនៅឋានផ្ទាល់ខ្លួនតាមបណ្ដារាជធានី ខេត្ត និងសាងសង់នៅលើដីសម្បទានសង្គមកិច្ចចំនួន១៤ខេត្ត រួមមាន ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្ដរមានជ័យ ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ និងខេត្តកោះកុង (២)- សាលារៀនចំនួន១ខ្នង មាន៦បន្ទប់ នៅមណ្ឌលអភិវឌ្ឍន៍យោធិនពិការ៣១៧ តេជោភ្នំធំត្រ និង(៣)- សាលារៀនចំនួន១ខ្នង មាន១២បន្ទប់ អគារទីចាត់ការចំនួន១ខ្នង អគារស្នាក់នៅគ្រូចំនួន១ខ្នង មាន២០បន្ទប់ អគារជំងឺទូទៅចំនួន១ខ្នង មាន១៦បន្ទប់ អគារវះកាត់ចំនួន១ខ្នង មាន៩បន្ទប់ និងអគារស្នាក់នៅពេទ្យចំនួន១ខ្នង មាន២០បន្ទប់ នៅភូមិប៊ុនរ៉ានីសែនជ័យដំណាក់ទ្រយឹង។

បានបន្សល់ទុកនូវអតីតយុទ្ធជនដែលជាជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារយុទ្ធជនពលីមរណៈជាច្រើន។ ចាប់តាំងពីក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តគោលនយោបាយនានា ដើម្បីលើកកម្ពស់សុខុមាលភាពនិងជីវភាពរស់នៅរបស់បងប្អូនអតីតយុទ្ធជន និងនិវត្តជន ដែលជាអតីតមន្ត្រីរាជការស៊ីវិលឱ្យបានល្អប្រសើរជាបន្តបន្ទាប់។ ប៉ុន្តែថ្មីៗនេះ សកម្មភាពខុសច្បាប់របស់កងកម្លាំងប្រដាប់អាវុធថៃប្រឆាំងនឹងអធិបតេយ្យនិងបូរណភាពទឹកដីកម្ពុជាចូលហួសខ្សែបន្ទាត់ព្រំដែន ដោយបានបើកប្រតិបត្តិការវាយសំរុកចូលទន្ទ្រាន កាន់កាប់ និងឈរជើងក្នុងទឹកដីកម្ពុជាដោយឃោរឃៅ ដែលបានគិតទុកជាមុន និងជាប្រព័ន្ធមកលើទីតាំងជាច្រើនតាមបណ្តោយព្រំដែន ដែលមានការទទួលស្គាល់ជាអន្តរជាតិ។ សកម្មភាពឃោរឃៅថៃប្រកបដោយអរិភាពនៅតាមបណ្តោយព្រំដែននិងនៅក្នុងទឹកដីកម្ពុជា បានវាយកម្ទេចសំណង់ស៊ីវិល ផ្ទះសម្បែងរបស់ប្រជាជន និងហេដ្ឋារចនាសម្ព័ន្ធស៊ីវិល ដោយបន្តបិទសិទ្ធិរបស់ជនភៀសសឹកកម្ពុជាជាច្រើនមិនឱ្យត្រឡប់ទៅលំនៅឋានវិញ គឺជាការរំលោភយ៉ាងជាក់ច្បាស់ចំពោះគោលការណ៍ជាមូលដ្ឋាននៃច្បាប់អន្តរជាតិ ក៏ដូចជាច្បាប់មនុស្សធម៌ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ តែទោះបីជាយ៉ាងណា រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាដល់យុទ្ធជនពលី ប្រជាជនស្លូតត្រង់ និងស្តារហេដ្ឋារចនាសម្ព័ន្ធឡើងវិញ ទាំងតាមរយៈព្រឹត្តិការណ៍ដែលបានកើតឡើងពីអតីតកាលក៏ដូចជាបច្ចុប្បន្ន។ គ្រប់ស្ថាប័នរដ្ឋ ឯកជន និងប្រជាជនទូទៅ បានបង្ហាញនូវសាមគ្គីភាពជាធ្លុងមួយក្នុងការជួយឧបត្ថម្ភគាំទ្រទាំងសម្ភារៈនិងស្មារតីដល់វីរៈកងទ័ពនិងជនភៀសសឹក និងបានផ្តល់អាទិភាពដល់បងប្អូនអតីតយុទ្ធជន និវត្តជន និងក្រុមគ្រួសារក្នុងការទទួលបាននូវសេវាសាធារណៈផ្សេងៗ រួមទាំងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាមរាជរដ្ឋាភិបាលនិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ជាអនុប្រធានទី១ សមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា ខ្ញុំសូមលំឱនកាយគោរពចំពោះវិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារី បងប្អូនអតីតយុទ្ធជន ដែលបានធ្វើពលិកម្ម បូជាសាច់ស្រស់ ឈាមស្រស់ ដើម្បីបុព្វហេតុការពារជាតិ មាតុភូមិ និងប្រជាជនជាទីស្នេហារបស់យើងនៅគ្រប់ដំណាក់កាល។ ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ និងគ្រប់ប្រភេទនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិដែលបាននិងកំពុងបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមក្នុងបុព្វហេតុអភិវឌ្ឍប្រទេសជាតិនិងការពារបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

នៅគ្រប់កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល តែងតែផ្តល់ការយកចិត្តទុកដាក់លើការងារអតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិលជាអាទិភាពមួយក្នុងចំណោមអាទិភាពនានា។ ដោយឡែក រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ដែលក្នុងនោះ ការអភិវឌ្ឍវិស័យសង្គមកិច្ចស្ថិតនៅក្នុងបញ្ចកោណទី១នៃយុទ្ធសាស្ត្រ : ការអភិវឌ្ឍមូលធនមនុស្ស ក្នុងមុំទី៤ ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង មានគោលដៅជាយុទ្ធសាស្ត្រ គឺការកសាងនិងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈប្រមូលផ្តុំនិងសង្គតិភាពទាំងក្នុងប្រព័ន្ធជំនួយសង្គមនិងប្រព័ន្ធសន្តិសុខសង្គម និងការពង្រឹងប្រព័ន្ធស្បៀងដែលផ្តល់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភសម្រាប់ប្រជាជនគ្រប់រូប។ ការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឈរលើស្មារតី«មិនបោះបង់ពលរដ្ឋខ្មែរណាម្នាក់» ហើយការពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គមឈរលើអភិក្រមចំនួន៤ គឺ (១)- ចីរភាពនៃកម្មវិធី (២)- លទ្ធភាពអាចទ្រទ្រង់បាននៃថវិកាជាតិ (៣)- ការធានាបរិយាបន្ន និងសមធម៌សង្គមដោយផ្តោតលើកិច្ចអន្តរាគមន៍របស់រដ្ឋលើគ្រួសារក្រីក្រ ងាយរងគ្រោះ និងងាយរងហានិភ័យ និង (៤)- ភាពអាចពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គម តាមរយៈការអភិវឌ្ឍជាប្រព័ន្ធ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦ សលខ

# សារលិខិត

## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសទិវាអតីតយុទ្ធជន និងនិវត្តជនកម្ពុជា លើកទី១៩
## ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៦

- **សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចសង្ឃនាយក ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**
- **សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**
- **សូមក្រាបថ្វាយបង្គំព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**
- **សម្តេច ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ តំណាងរដ្ឋាភិបាលនៃបណ្តាប្រទេសជាមិត្ត និងអង្គការអន្តរជាតិទាំងអស់ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា**
- **បងប្អូនអតីតយុទ្ធជន និវត្តជន និងជនរួមជាតិទាំងអស់ ជាទីរាប់អាន**!

ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៦ គឺជាទិវាប្រវត្តិសាស្ត្រប្រកបដោយមោទនភាពបំផុត ដែលបងប្អូនអតីតយុទ្ធជន និវត្តជន និងប្រជាពលរដ្ឋនៅទូទាំងព្រះរាជាណាចក្រកម្ពុជា បានប្រារព្ធទិវាអតីតយុទ្ធជន និងនិវត្តជនកម្ពុជា លើកទី១៩ អនុលោមតាមស្មារតីនៃអនុក្រឹត្យលេខ១៤៥ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ស្តីពីទិវាអតីតយុទ្ធជន និងនិវត្តជនកម្ពុជា ក្នុងគោលបំណងលើកតម្កើងវីរភាពដ៏អង់អាចក្លាហាន និងគុណបំណាច់ដ៏ធំធេងរបស់អតីតយុទ្ធជន និងនិវត្តជនកម្ពុជា ដែលបានធ្វើពលិកម្ម បូជាសាច់ស្រស់ ឈាមស្រស់ ដើម្បីបុព្វហេតុជាតិមាតុភូមិ និងប្រជាជន។ ពលិកម្មប្រកបដោយស្មារតីស្នេហាជាតិរបស់វីរអតីតយុទ្ធជន យុទ្ធនារី កងកម្លាំងប្រដាប់អាវុធ និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និងប្រជាពលរដ្ឋយើងនៅគ្រប់ដំណាក់កាលនៃប្រវត្តិសាស្ត្រ បានរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចការពារបូរណភាពទឹកដី ការកសាងសុខសន្តិភាព និងស្ថិរភាពសង្គមសម្រាប់ព្រះរាជាណាចក្រកម្ពុជា សំដៅធានាឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមដើម្បីជាឧត្តមប្រយោជន៍សម្រាប់ជាតិមាតុភូមិ និងប្រជាជន។

សង្គ្រាមដែលបង្កឡើងដោយជនក្បត់ជាតិឃុបឃិតជាមួយបរទេស បានបណ្តាលឱ្យមានវិនាសកម្មនិងបង្កើតឱ្យមានរបបប្រល័យពូជសាសន៍ ប៉ុលពត ព្រមទាំងបានបំផ្លិចបំផ្លាញសង្គម សេដ្ឋកិច្ចឱ្យខ្ទេចខ្ទីដល់ឫសគល់ ថែមទាំង